ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំសឹង្ហបុរី

លេខ: 063 សកសប

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**តាមរយៈ:** **ការិយាល័យ:** ការៈធារីស្តីធី

**កម្មវត្ថុ:** ស្តីពីសកម្មភាពការងាររបស់អនុព័ន្ធពាណិជ្ជកម្ម អមស្ថានទូតព្រះរាជាណាចក្រកម្ពុជានៅប្រទេសសឹង្ហបុរីប្រចាំខែ កុម្ភៈ ឆ្នាំ ២០១៣ ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបស្តីពីសកម្មភាពការងាររបស់អនុព័ន្ធពាណិជ្ជកម្ម អមស្ថានទូតព្រះរាជាណាចក្រកម្ពុជានៅប្រទេសសឹង្ហបុរីប្រចាំខែ កុម្ភៈ ឆ្នាំ ២០១៣ ដូចខាងក្រោមៈ

-កាលពីថ្ងៃទី **០១ ខែ កុម្ភៈ ឆ្នាំ ២០១៣** បានចូលរួមកម្មវិធីប្រគល់ពានរង្វាន់ប្រចាំឆ្នាំលើកទី ២៦ នៃ Singapore 1000 & SME 1000 Inc Singapore International 100 Gala Award ដែលរៀបចំដោយក្រុមហ៊ុន DP Information Group ដោយមានវត្តមាន ឯកឧត្តម TEO Ser Luck អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មសឹង្ហបុរី អញ្ជើញចូលរួមជាភ្ញៀវកិត្តិយស។

-កាលពីថ្ងៃទី **០៥ ខែ កុម្ភៈ ឆ្នាំ ២០១៣** បានទៅចូលរួមស្តាប់សន្ទរកថាដែលរៀបចំឡើងដោយអាជ្ញាធររូបិយវត្ថុសឹង្ហបុរី ស្តីពី The quest for successful policy response to sovereign crises ដោយថ្លែងសន្ទរកថាដោយឯកឧត្តម Agustin Carstens ទេសាភិបាលធនាគារជាតិប្រទេសម៉ិកស៊ិក និងមានវត្តមានអញ្ជើញចូលរួមជាកិត្តិយសរបស់ ឯកឧត្តមទេសរដ្ឋមន្ត្រី Goh Chok Tong។

-កាលពីថ្ងៃទី **១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣** បានចូលរួមកម្មវិធីអាហារពេលល្ងាចដើម្បីអបអរចូលឆ្នាំចិនថ្មីឆ្នាំរកដែលរៀបចំដោយការិយាល័យពាណិជ្ជកម្ម និង សេដ្ឋកិច្ចហុងកុងប្រចាំនៅប្រទេសសឹង្ហបុរី។

-កាលពីថ្ងៃទី **២០ ខែ កុម្ភៈ ឆ្នាំ ២០១៣** បានចូលរួមសិក្ខាសាលាស្តីពី Whither ASEAN: Developments and Opportunity in ASEAN an potential pitfalls for business ដែលរៀបចំដោយសហព័ន្ធអ្នកផលិតសឹង្ហបុរី (Singapore Manufacturer's Federation)។

-កាលពីថ្ងៃទី **២១ ខែ កុម្ភៈ ឆ្នាំ ២០១៣** បានចូលរួមស្តាប់បទឧទ្ទេសនាម SMU Presidential Distinguished Lecturer Series ស្តីពី Winning in emerging market: A



Address : 400 Orchard Road, #10-03/04, Orchard Towers, Singapore 238875
Website : http://home.pacific.net.sg/~recambodia.sg
Tel: (65) 63419785 , Fax: (65) 63419201
E-mail: cambodiaembasy@pacific.net.sg

roadmap for strategy & execution ដោយធ្វើបទឧទ្ទេសនាមបង្ហាញដោយសាស្ត្រាចារ្យ Tarun Khanna នាយកវិទ្យាស្ថានអាស៊ីខាងត្បូង នៃUniversity of Harvard។

-កាលពីថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ បានចូលរួមកម្មវិធីអាហារពេលថ្ងៃដើម្បីអបអរចូលឆ្នាំចិនថ្មីឆ្នាំរកដែលរៀបចំដោយ Fraser Hospitality។

-កាលពីថ្ងៃទី ២២-២៣ ខែ កុម្ភៈ ឆ្នាំ ២០១៣ បានចូលរួមសិក្ខាសាលាស្តីពី Asia Pacific Economic Integration and Connectivity ដែលរួមគ្នារៀបចំឡើងដោយ Pacific Economic Cooperation Council (PECC) Singapore National Committee for Pacific Economic Cooperation Council (SINPECC) និង Indonesian National Committee for Pacific Economic Cooperation Council (INPECC) ដោយមានវត្តមានជាកិត្តិយសរបស់ឯកឧត្តម LIM Hng Kiang រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និង ឧស្សាហកម្មសឹង្ហបូរី ថ្លែងសន្ទរកថាបើក និង សន្ទនា។

-កាលពីថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ បានចូលរួម SMU-IEs-MIGA Summit ស្តីពី Managing Global Political Risk ដែលរួមគ្នារៀបចំដោយ Singapore Management University (SMU) International Enterprises Singapore (IEs) និង Multilateral Investment Guaranty Agency (MIGA)។

-កាលពីថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ បានចូលរួមធ្វើបទបង្ហាញស្តីពីសក្តានុពលនៃការធ្វើពាណិជ្ជកម្ម និងវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរួមគ្នារៀបចំដោយក្រុមហ៊ុន DP Information Group និងក្រុមហ៊ុន DHL ដោយមានអ្នកចូលរួមប្រមាណជាង ៩០ នាក់ ដែលជាពាណិជ្ជករ និង អ្នកគ្រប់គ្រងក្រុមហ៊ុន។

-កាលពីថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ បានជួបពិភាក្សាការងារជាមួយលោក Choy Yoke Chuen ក្រុមហ៊ុន Heap Heng Metal និង លោក Sham Weng Heng អ្នកពិគ្រោះយោបល់នៃក្រុមហ៊ុន AMG Contract Service ដែលមានទីតាំងនៅប្រទេសសឹង្ហបូរី ដែលមានបំណងទៅវិនិយោគនៅប្រទេសកម្ពុជា ក្នុងការបើករោងចក្រតម្លើងសម្ភារៈប្រើប្រាស់ធ្វើពីដែកដើម្បីនាំចេញ។

-កាលពីថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ បានចូលរួម TFCTN Public Lecture ស្តីពីគោលនយោបាយសេដ្ឋកិច្ចសហរដ្ឋអាមេរិក ដែលរៀបចំដោយ មជ្ឈមណ្ឌលមូលនិធិ Temasek សម្រាប់ពាណិជ្ជកម្ម និង ការចរចារ និងសភាពាណិជ្ជកម្មអាមេរិកប្រចាំនៅប្រទេសសឹង្ហបូរី ដោយមានការអញ្ជើញចូលរួមជាកិត្តិយសរបស់ឧបការីក្រសួងសេដ្ឋកិច្ច និងកិច្ចការពាណិជ្ជកម្មសហរដ្ឋអាមេរិក លោក Jose Fernandez ជាវាគ្មិន និង កិច្ចសន្ទនាស្តីពីគោលនយោបាយរបស់សហរដ្ឋអាមរិកលើប្រទេសមីយ៉ាន់ម៉ា និង សក្តានុពលវិនិយោគ និងគោលបំណងក្នុងការបញ្ចប់ការចរចារដៃគូអន្តរប៉ាស៊ីហ្វិក (Trans-Pacific Partnership)នៅក្នុងឆ្នាំ ២០១៣នេះ។

-កាលពីថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ បានចូលរួមស្តាប់កិច្ចសន្ទនា Post-Budget 2013 ដែលរួមដឹកនាំដោយ លោកជំទាវ Josephine TEO អនុរដ្ឋលេខាធិការក្រសួងហិរញ្ញវត្ថុ និង ដឹកជញ្ជូនសឹង្ហបូរី និង លោកជំទាវ Amy KHOR ប្រធានអង្គភាព REACH (Reach for

Everyone for Active Citizenry at Home) ដែលពិភាក្សាផ្លាស់ប្តូរគំនិតយោបល់លើថវិកាឆ្នាំ ២០១៣របស់សឹង្ហបូរី ដែលបានប្រកាសផ្សាយដោយឯកឧត្តម Tharman Shanmugaratnam ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ កាលពីថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៣។

អាស្រ័យដូចបានជំរាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីរូបខ្ញុំបាទ។

សឹង្ហបូរី, ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៣

**អនុព័ន្ធពាណិជ្ជកម្ម**

**ម៉ៅ សាគល**

**បានឃើញ និង ឯកភាព**

**គោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

សឹង្ហបូរី, ថ្ងៃទី 05 ខែ មីនា ឆ្នាំ ២០១៣

**ភារៈធារីស្តីទី**

**រស់ ស៊ីម៉ារ៉ា**

**ចម្លងជូន:**

-ក្រសួងពាណិជ្ជកម្ម

-ឯកសារ-កាលប្បវត្តិ